ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ...០៥៥..........អ.ស.ហ.ប្រក

# ប្រកាស
## ស្តីពី
## ការតែងតាំងប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាល អាណត្តិទី៧ របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- យោងតាមសំណើរបស់អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) អាណត្តិទី៧ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. លោក **ឃុន ដារិទ្ធ** | ប្រធាន |
| ២. លោក **នៅ រ៉េមី** | អនុប្រធាន |
| ៣. ឯកឧត្តម **ប៊ូ ថារិន** | សមាជិក |
| ៤. ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** | សមាជិក |
| ៥. កញ្ញា **សុខ ស្រីរដ្ឋា** | ហេរញ្ញិក |
| ៦. លោកជំទាវ **ថៃ សុខផល្លីន** | សមាជិក |
| ៧. ឯកឧត្តម **លី ណារុឌ្ឍ** | សមាជិក |
| ៨. លោកស្រី **តាន់ លីនណា** | សមាជិក |
| ៩. លោក **ខាង ហុង** | សមាជិក |
| ១០. លោកស្រី **ស៊ុន គីមហ៊ីន** | សមាជិក |
| ១១. លោក **លី ប៊ុនសោម** | សមាជិក |
| ១២. លោក **គង់ ស៊ិនវ៉ា** | សមាជិក |
| ១៣. លោក **ជៀម គីមហួ** | សមាជិក |
| ១៤. លោក **ស្រេង វុទ្ធី** | សមាជិក |
| ១៥. លោក **តឹក សុខវាសនា** | សមាជិក |
| ១៦. លោក **ហួរ វរៈបុត្ត** | សមាជិក |
| ១៧. កញ្ញា **ដូ សុខឡេង** | សមាជិក |
| ១៨. លោកស្រី **សាវុធ ដាលី** | សមាជិក និងជាលេខាធិការ។ |

**ប្រការ២.-**

អាណត្តិទី៧ របស់ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ **វ.គ.ស.ក.** មានរយៈពេល ០៤ (បួន) ឆ្នាំដោយគិតចាប់ថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៣.-**

ប្រកាសលេខ៩០៩ សហវ.ប្រក ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការកែសម្រួលសមាសភាព

នៃក្រុមប្រឹក្សាភិបាល អាណត្តិទី៦ របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា គ.ស. ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
- និយ័តករគណនេយ្យនិងសវនកម្ម
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ